

## ជំពូកទី៧

# ការជ្រើសរើស និង ការរៀនភាសា

នៅពេលកុមារទម្លាប់ខ្លួនប្រើមូលដ្ឋានបំណិនប្រាស្រ័យទាក់ទងបានស្រួលបួល ដូចបានរៀបរាប់នៅក្នុងជំពូកទី4 គឺកុមារបានត្រៀមរៀនភាសាមួយជាស្រេចហើយ។ ដំបូងកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អអាចរៀនភាសាសញ្ញាមួយ (សូមអានជំពូកទី៨) ឬរៀនភាសានិយាយមួយ (សូមអានជំពូកទី៩)។ ទោះកុមាររៀនភាសាណាមួយក៏ដោយ ភាសានោះត្រូវតែជួបនឹងតម្រូវការរបស់កុមារ។

ភាសាមួយណាដែលកុមាររៀនមុនគេ នឹងពឹងផ្អែកលើអ្វីៗជាច្រើនដូចជា តើកុមារអាចស្តាប់ឮបានច្រើនក៏រិតណា ភាសាមួយណាដែលកុមារពេញចិត្តរៀន លទ្ធភាពកុមារផ្ទាល់ពីកំណើត និងធនធានដែលមាននៅក្នុងសហគមន៍របស់កុមារ។ វាក៏ពឹងផ្អែកលើរបៀបដែលឪពុកម្តាយឆ្លើយតបទៅនឹងភាពថ្លង់របស់កូនផងដែរ។ ការស្គាល់មនុស្សថ្លង់នៅក្នុងសហគមន៍អាចជួយឪពុកម្តាយឱ្យព្រមទទួលយកភាពថ្លង់របស់កូន និងរកវិធីនានាដើម្បីជួយកុមាររៀនភាសាមួយផងដែរ។

នៅកន្លែងទាំងឡាយណាដែលមានធនធានតិចតួចសំរាប់កុមារថ្លង់ ឪពុកម្តាយអាចមានអារម្មណ៏ថា ពួកគាត់គ្មានជំរើសអំពីភាសាមួយណាដែលកូនគាត់អាចរៀនបាន។ បើសិនជាអ្នកដាក់តម្រូវការ និងលទ្ធភាពរបស់កូនជាអាទិភាពទីមួយ អ្នកនឹងធ្វើការសំរេចចិត្តល្អបំផុតដែលអ្នកអាច។




វាមិនមែនជាការងាយស្រួលដឹងនោះទេ
ថាអ្វីដែលល្អបំផុតសំរាប់កុមារ.....
ប៉ុន្តែអ្នកត្រូវតែសាកល្បងវា។

## ការរៀនភាសាឱ្យទាន់ពេល គឺជាការសំខាន់

ឆ្នាំសិក្សាល្អបំផុតសំរាប់រៀនភាសា គឺចាប់ពីថ្ងៃកើតដល់អាយុ7ឆ្នាំ។ ធម្មតា កុមារស្ទើរតែទាំងអស់រៀនភាសាចាប់ពីចន្លោះអាយុ2ទៅ4ឆ្នាំ។ បើសិនជាកុមារមិនបានរៀនភាសា ពេលអាយុប្រមាណ7ទៅ8ឆ្នាំ កុមារនឹងពិបាកច្រើនសំរាប់ការរៀនភាសាទៅថ្ងៃមុខ។ បើសិនជាកុមារថ្លង់ម្នាក់ មិនបានរៀនភាសានិយាយមួយ ឬភាសាសញ្ញាមួយ កុមារនោះនឹងជួបការលំបាកក្នុងការអភិវឌ្ឍបំណិនការគិតឱ្យបានពេញលេញ។ នោះជាហេតុផលដែលថា ការរៀនភាសាគឺជាការសំខាន់។

### របៀបរៀនភាសារបស់កុមារ

ភាសាប្រើនិមិត្តសញ្ញាដូចជាសម្លេង ការសរសេរ ឬសញ្ញា ដែលអនុញ្ញាតឱ្យមនុស្សប្រាស្រ័យទាក់ទងជាមួយគ្នាទៅវិញទៅមកបាន។ ការអាន ការសរសេរ ការនិយាយ និងការធ្វើសញ្ញា គឺជាការប្រើភាសាជានិច្ច។

ជំហានដំបូងដែលកុមារចាប់ផ្ដើមរៀនភាសា គឺរៀនឈ្មោះមនុស្ស និងពាក្យសំរាប់របស់របរដែលកុមារមើលឃើញរាល់ថ្ងៃ ដូចជាពាក្យ "ម៉ែ" "ឆ្មា" ឬ "កូនង៉ែត" ។ ប៉ុន្តែជាញឹកញាប់ ពាក្យទីមួយដែលកុមារនឹងនិយាយ គឺចង់ឱ្យអ្វីមួយកើតឡើង ដូចជាពាក្យ "ទឹកដោះគោ" "ទេ" ឬ "ព"។




**កុមារបានដឹងថា ពាក្យនិយាយមានអំណាចដើម្បីឱ្យអ្វីមួយកើតឡើង។ ជាការជំរុញទឹកចិត្តដ៏ខ្លាំងក្លា សំរាប់កុមារប្រាស្រ័យទាក់ទង និងទទួលអ្វីមួយដែលខ្លួនចង់បាន។**




ដំបូង កុមាររៀនពាក្យទោល។ បន្ទាប់ពួកគេរៀនពីឃ្លនដើម្បីប្រើពាក្យរួមគ្នា។ រយៈកាលកន្លងមក កុមារបានរៀនឃ្លនៃភាសាក្នុងពេលដែលពួកគេប្រើភាសាជាមួយមនុស្សឯទៀត។

កុមាររៀនភាសាដោយការស្ដាប់ និងឃើញភាសាផ្សេងៗជុំវិញខ្លួន ហើយនឹងហាត់អនុវត្តអ្វីៗដែលបានឮ និងឃើញ។ កុមារអភិវឌ្ឍលទ្ធភាពគំនិតបញ្ញា ពេលពួកគេរៀនកាន់តែច្រើនទៅៗ ហើយប្រើវាទៅតាមលំដាប់ឃ្លនៃភាសា។ វាគឺជារឿងធម្មតាក្នុងការនិយាយខុស បន្ទាប់កុមារចាប់ផ្ដើមកែលំអ ធ្វើឱ្យការប្រាស្រ័យទាក់ទងរបស់ពួកគេកាន់តែជោគជ័យ។




**កុមាររៀនប្រើភាសាដោយអនុវត្តជាមួយមនុស្សឯទៀត។**

## ភាសា និងការគិតអភិវឌ្ឍរួមគ្នា

ភាសាអនុញ្ញាតឱ្យយើងប្រាស្រ័យទាក់ទងជាមួយមនុស្សឯទៀត។ វាក៏អនុញ្ញាតឱ្យយើងប្រាស្រ័យទាក់ទងជាមួយខ្លួនឯងផងដែរ។ ភាសាដែលកុមារបានរៀនកាលពីនៅតូច គឺជាឧបករណ៏ដែលកុមារអភិវឌ្ឍការគិតរបស់ខ្លួន ភាសាដែលកុមារប្រើដើម្បីនិយាយរកខ្លួនឯង។ ទោះបីជាយើងគិតបែបណាក៏ដោយ ក៏ត្រូវពឹងផ្អែកលើភាសាដែលយើងចេះបានច្រើនប៉ុណ្ណា ហើយយើងអាចប្រើវាបានច្រើនប៉ុណ្ណា។



***ដានីញ៉ែល*** គឺជាកុមារថ្លង់។ ***ដានីញ៉ែល***អាចប្រាស្រ័យទាក់ទងបានតិចតួចតាមរយៈកាយវិការ សំដែងទឹកមុខ និងតាមរយៈសញ្ញាដែលក្រុមគ្រួសារបានប្រឌិតឡើង។ នេះជាអ្វីដែល***ដានីញ៉ែល***អាចប្រាប់ម្តាយអំពីអ្វីដែលគេជួបប្រទះនៅថ្ងៃនេះ :-




បើសិនជា ***ដានីញ៉ែល*** និងក្រុមគ្រួសារមានភាសាតែមួយសំរាប់ប្រើរួមគ្នា ពួកគេអាចប្រាស្រ័យទាក់ទងបានច្រើនជាងនេះ ហើយលទ្ធភាពការគិត និងធ្វើផែនការរបស់***ដានីញ៉ែល***នឹងរីកចំរើនឡើង។






កាលណាកុមារអាចរៀនភាសាមួយបានច្រើន ទោះជាពួកគេនិយាយ ឬធ្វើសញ្ញាក៏ដោយ នោះពួកគេអាចយល់ព្រឹត្តិការណ៏ដែលនៅជុំវិញខ្លួន សំដែងអារម្មណ៏របស់ខ្លួន គិត សង្ឃឹម ធ្វើផែនការ និងប្រាស្រ័យទាក់ទងជាមួយមនុស្សម្នាជុំវិញពួកគេបានច្រើនទៅតាមនោះដែរ។

**កុមារអភិវឌ្ឍការគិតរបស់ពួកគេនៅពេល :-**

- ពួកគេឃើញ ឬស្តាប់ឮមនុស្សប្រើពាក្យ ឬសញ្ញាដើម្បីផ្លាស់ប្តូរព័ត៌មាន។
- ពួកគេប្រើភាសាដើម្បីពណ៌នាអ្វីមួយដែលពួកគេបានឃើញ ស្តាប់ឮ និងប៉ះ ឬស្ទាប។
- ពួកគេប្រើភាសាដើម្បីសំដែងបទពិសោធន៍ដែលធ្លាប់ជួបប្រទះ។
- ពួកគេប្រើភាសាដើម្បីផ្សារភ្ជាប់រវាងអ្វីមួយ។




***ម៉ាយ៉ា* អភិវឌ្ឍបំណិនការគិតរបស់នាងដោយបានឮមនុស្សប្រើភាសាដើម្បីរៀបរាប់ពីការគិត និងគំនិត។**




**កុមារអភិវឌ្ឍបំណិនការគិតជាជំហានៗ**




ដំបូង កុមារតូចរៀនបំណិនការគិតសាមញ្ញៗដោយការលេងកំសាន្ត។ ឧទាហរណ៍កុមាររៀនពាក្យ "តូច" និង "ធំ"។ បន្ទាប់មក កុមារប្រើពាក្យទាំងនោះដើម្បីយល់ថា គឺមានបាល់មួយ "តូច" និងបាល់មួយ "ធំ"។




បន្ទាប់មក ពេលកុមារយល់របៀបប្រៀបធៀប "តូច" និង "ធំ" កុមារអាចចាប់ផ្តើមគិតអំពីវត្ថុផ្សេងៗទៀតដែល "តូច" ឬ "ធំ"។ កុមាររៀនគិតអំពី "ទំហំ"។

## មូលដ្ឋានចំណេះនៃការគិត និងភាសា

ខណៈដែលពួកគេរៀនភាសា កុមាររៀបចំការគិតរបស់ខ្លួន និងធ្វើការផ្សារភ្ជាប់រវាងគំនិតខុសៗគ្នា :-

- របៀបដែលវត្ថុ បុគ្គល ឬព្រឹត្តិការណ៍ បង្កហេតុឱ្យអ្វីមួយទៀតកើតឡើង ។




- បើខ្ញុំប្រើឈើមួយ ខ្ញុំអាចឆ្កឹះយកបាល់បាន ។




- របៀបរៀបចំវត្ថុតាមលំដាប់លំដោយ ។




- របៀបរាប់ចំនួន ។




- របៀបកត់សំគាល់ប្រភេទនៃកម្មវត្ថុ ដើម្បីរៀនពាក្យមួយដែលអាចមានន័យខុសគ្នា និងពាក្យពីរបីដែលមានន័យដូចគ្នា ។




- របៀបពិពណ៌នាអារម្មណ៍បុគ្គលម្នាក់ និងហេតុអ្វីបានជាគាត់មានអារម្មណ៍បែបនោះ?




វាជាការសំខាន់ដែលការរៀនភាសាក្លាយជាចំណែកនៃជីវិតកុមារថ្លង់ ឬមិនអាចស្តាប់ឮ ។ ឪពុកម្តាយ ភ្នាក់ងារសហគមន៍ និងគ្រូបង្រៀនត្រូវតែលើកទឹកចិត្តកុមារឱ្យរៀន និងប្រើភាសាមួយដើម្បីសំដែងអារម្មណ៍របស់ពួកគេ ប្រាស្រ័យទាក់ទងជាមួយអ្នកផ្សេង និងអភិវឌ្ឍលទ្ធភាពនៃគំនិតបញ្ញារបស់ពួកគេ ។

## ភាសាសញ្ញា និងភាសានិយាយ

ភាសាទាំងពីរប្រភេទដែលកុមារថ្លង់ ឬកុមារមិនអាចស្តាប់ឮល្អអាចរៀនគឺ :-

- **ភាសាសញ្ញា** នៅពេលដែលកុមារប្រើដៃដើម្បីប្រាស្រ័យទាក់ទងជាមួយសហគមន៍ គឺសញ្ញាដែលបានប្រើដោយសហគមន៍មនុស្សថ្លង់នៅក្នុងតំបន់ ឬប្រទេសដែលកុមាររស់នៅ ។
- **ភាសានិយាយ** នៅពេលដែលកុមារប្រើសម្លេងនិយាយ និងអានតាមបបូរមាត់ ដើម្បីប្រាស្រ័យទាក់ទងជាភាសានិយាយនៅក្នុងតំបន់ ឬប្រទេសនោះ ។

កុមារមួយចំនួនដែលស្តាប់ឮតិចៗអាចចេះនិយាយ និងអានដោយមើលមាត់ ។ កុមារឯទៀតប្រាស្រ័យទាក់ទងបានល្អប្រសើរដោយធ្វើសញ្ញានឹងដៃរបស់ខ្លួន ។ អ្នកអាចចាប់ផ្តើមជាមួយភាសាមួយ និងបង្រៀនកូនដោយវិធីផ្សេងទៀត ដើម្បីប្រាស្រ័យទាក់ទងនៅពេលកូនកាន់តែធំ ។




**ឧទាហរណ៍ :-**

មនុស្សជាច្រើនចាប់ផ្តើមដោយប្រើកាយវិការ និងសញ្ញាជាមួយកុមារតូច ជាពិសេស បើសិនជាពួកគាត់មិនប្រាកដថា កុមារអាចស្តាប់ឮសម្លេងនិយាយ ។ បន្ទាប់មកពេលកុមារកាន់តែធំទៅ និងយល់សញ្ញាខ្លះៗ ពួកគេអាចព្យាយាមបង្រៀនកុមារឱ្យចេះអានដោយមើលមាត់ និងនិយាយ ។




មនុស្សឯទៀត ចាប់ផ្តើមដោយប្រើការនិយាយ និងអានដោយមើលមាត់ បើសិនជាពួកគេដឹងថា កូនរបស់ខ្លួនអាចស្តាប់ឮបានខ្លះៗ ឬបើសិនជាកុមារក្លាយជាមនុស្សថ្លង់ក្រោយពេលចេះនិយាយហើយ ។ ពេលកុមារមិនបានរៀនភាសានិយាយមួយរយៈកាល នោះអាចមានន័យថាភាសាសញ្ញា គឺជាវិធីល្អប្រសើរសំរាប់កុមារ ។

**ភាសាដែលកូនរបស់អ្នកប្រើ អាចពឹងផ្អែកលើ :-**

- កូនរបស់អ្នកអាចស្តាប់ឮបានច្រើនប៉ុណ្ណា និងតិចប៉ុណ្ណា ។
- ភាសាណាមួយ ដែលកូនពេញចិត្ត ។
- ប្រតិកម្មរបស់អ្នក ចំពោះភាពថ្លង់របស់កូន ។
- នៅពេលណាកូនចាប់ផ្តើមមានការពិបាកក្នុងការស្តាប់ ។
- ធនធានដែលមាននៅក្នុងក្រុមគ្រួសារ និងសហគមន៍របស់អ្នក ។

## ការប្រើភាសាសញ្ញា




ភាសាសញ្ញា គឺបានប្រើដោយមនុស្សថ្លង់នៅទូទាំងសហគមន៍ ។ វាជាភាសាមួយដែលប្រើទ្រង់ទ្រាយដៃ ចលនារាងកាយ កាយវិការ និងការសំដែងទឹកមុខ ដើម្បីប្រាស្រ័យទាក់ទងពីបទពិសោធន៍ ការគិត តម្រូវការ និងអារម្មណ៍ ។ ភាសាសញ្ញារួមទាំងកាយវិការ ក៏ដូចជាសញ្ញារាប់ពាន់ដែលមនុស្សថ្លង់បានអភិវឌ្ឍកន្លងមក ។

ភាសាសញ្ញា គឺជាភាសាមួយពិតប្រាកដដែលមានរបៀបចំវេយ្យាករណ៍ និងរចនាសម្ព័ន្ធដូចភាសានិយាយអញ្ចឹងដែរ ។ មនុស្សប្រើវាដើម្បីសួរសំណួរស្មុគស្មាញពណ៌នាអ្វីៗដែលនៅជុំវិញខ្លួន និងពិភាក្សាទំនាក់ទំនង គំនិត និងជំនឿ ។ មនុស្សប្រើភាសាសញ្ញាដើម្បីពិភាក្សាពីរបៀបដែលអ្វីមួយមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមក ឬសំដៅទៅអតីតកាល ឬអនាគត ។ មនុស្សដែលប្រើភាសាសញ្ញាមួយពេញលក្ខណៈអាចប្រាស្រ័យទាក់ទងបានគ្រប់អ្វីៗទាំងអស់ ដូចមនុស្សស្តាប់ឮអាចប្រាស្រ័យទាក់ទងដោយប្រើពាក្យនិយាយអញ្ចឹងដែរ ។

វិធីមួយដែលធ្វើឱ្យភាសាសញ្ញា ប្រហែលជាខុសប្លែកពីភាសានិយាយក្នុងស្រុកគឺលំដាប់សញ្ញាក្នុងឃ្លាមួយ ជាញឹកញាប់ខុសពីលំដាប់ពាក្យនិយាយ ។ ឧទាហរណ៍ សំណួរមួយ "តើអ្នកឈ្មោះអ្វី?" ជាភាសាសញ្ញាកម្ពុជា វានឹងមានលំដាប់បែបនេះ :-




មនុស្សថ្លង់ស្ទើរតែគ្រប់ប្រទេសនៅទូទាំងពិភពលោក បានបង្កើតភាសាសញ្ញាពេញលក្ខណៈដោយផ្ទាល់ ដូចភាសានិយាយអញ្ចឹងដែរ ភាសាសញ្ញាពេញលក្ខណៈ គឺខុសប្លែកគ្នាពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយទៅប្រទេសមួយ ។

នេះជាឧទាហរណ៍សញ្ញាសំរាប់ "ម្តាយ" នៃប្រទេសចំនួនបីខុសគ្នា ។




ទោះបីជាពួកវាខុសពីគ្នាក៏ដោយ ភាសាសញ្ញានីមួយៗគឺមានលក្ខណៈពេញលេញ និងតាមធម្មជាតិសំរាប់មនុស្សថ្លង់ប្រាស្រ័យទាក់ទង ។

## ផលប្រយោជន៍នៃការប្រើភាសាសញ្ញា



- កុមារតូចៗរៀនភាសាសញ្ញាយ៉ាងងាយស្រួល ពេលពួកគេបានដឹងអំពីវា។ កុមារធំៗ និងកុមារជំទង់អាចរៀន និងចេះប្រើភាសាសញ្ញាជាមួយការអនុវត្តដោយគ្មានបញ្ហាច្រើនឡើយ ។
- កុមារប្រើភាសាសញ្ញាអាចប្រាស្រ័យទាក់ទងជាមួយមនុស្សទាំងឡាយណាដែលចេះភាសាសញ្ញានោះដូចគ្នាបានពេញលេញ ដូចកុមារស្តាប់ឮម្នាក់ប្រើភាសានិយាយអញ្ចឹងដែរ ។ កុមារនឹងស្គាល់មនុស្សថ្លង់ផ្សេងៗទៀត និងដឹងថាមនុស្សថ្លង់ជាចំណែកសំខាន់មួយនៃសហគមន៍ ។
- កុមារចេះភាសាសញ្ញាម្នាក់ អាចមានការងាយស្រួលរៀនអាន និងសរសេរភាសានៃសហគមន៍របស់ខ្លួន។ កាលណាមនុស្សម្នាក់ចេះភាសាកាន់តែច្រើន បុគ្គលនោះងាយស្រួលរៀនភាសាផ្សេងទៀតកាន់តែច្រើនដែរ ។
- ភាសាសញ្ញាគឺខុសៗគ្នាមែន តែមនុស្សជាច្រើននៅជុំវិញពិភពលោកងាយស្រួលយល់វាណាស់ គឺមិនដូចភាសានិយាយនោះទេ។ ចំពោះកុមារប្រើភាសាសញ្ញាម្នាក់មកពីប្រទេសចិន ប្រាស្រ័យទាក់ទងជាមួយកុមារប្រើភាសាសញ្ញាម្នាក់ទៀតមកពីប្រទេសនីការ៉ាហ្គ័រ គឺពួកគេងាយយល់គ្នាច្រើនជាងមនុស្សស្តាប់ឮមកពីប្រទេសទាំងពីរនោះប្រាស្រ័យទាក់ទងគ្នាទៅទៀត ។

## ការលំបាកជាមួយការប្រើភាសាសញ្ញា



- កុមារប្រើភាសាសញ្ញា មិនអាចប្រាស្រ័យទាក់ទងជាមួយមនុស្សមិនចេះភាសាសញ្ញាបានឡើយ ។ ដើម្បីមានលទ្ធភាពប្រាស័យទាក់ទងជាមួយកូនរបស់អ្នក សមាជិកគ្រួសារ មិត្តភក្តិ និងមនុស្សឯទៀតក្នុងសហគមន៍ត្រូវតែប្រើភាសាសញ្ញាផងដែរ ។
- ខណៈដែលកុមារងាយស្រួលរៀនសញ្ញា មនុស្សធំត្រូវតែខំរៀនឱ្យបានច្រើន ដើម្បីចេះភាសាសញ្ញាពេញលេញមួយ ។
- បើសិនជាគ្រួសាររស់នៅក្នុងសហគមន៍មួយ ជាកន្លែងដែលគ្មានមនុស្សប្រើភាសាសញ្ញា ពួកគេអាចពិបាកស្វែងរកគ្រូបង្រៀនភាសាសញ្ញាម្នាក់ឬមនុស្សឯទៀតដើម្បីប្រើភាសាសញ្ញា ។

## ការប្រើភាសានិយាយ

មនុស្សស្ដាប់ឮប្រាស្រ័យទាក់ទងគ្នាដោយការនិយាយ និងស្ដាប់ឮមនុស្សឯទៀតនិយាយគ្នាជាភាសាក្នុងស្រុករបស់ពួកគេ ។ វាគឺជារឿងធម្មតាចំពោះក្រុមគ្រួសារទាំងឡាយ ដែលចង់ឱ្យកូនថ្លង់យល់ពាក្យសំដីរបស់ពួកគេ និងនិយាយរកពួកគេវិញដោយប្រើភាសានិយាយ (តាមមាត់) ។

ដើម្បីរៀនភាសានិយាយ កុមារមិនអាចស្ដាប់ឮល្អត្រូវ :-

- ប្រើការស្ដាប់ដែលនៅសេសសល់ ធ្វើដូច្នេះកុមារអាចយល់ពាក្យនិយាយ ។ ការប្រើឧបករណ៍ជំនួយការស្ដាប់អាចមានប្រយោជន៍សំរាប់កុមារ ។
- មើលមាត់បុគ្គលម្នាក់ពេលបុគ្គលនោះនិយាយ និងទាយពាក្យនិយាយនៃបុគ្គលនោះ (រៀនអានតាមបបូរមាត់) ។
- ហាត់និយាយពាក្យនោះ ធ្វើដូច្នេះមនុស្សឯទៀតនឹងយល់កុមារបានល្អប្រសើរ ។

ត្រូវចាំថា បើសិនជាអ្នកប្រើភាសានិយាយជាមួយកូន ក្រុមគ្រួសារ និងអ្នកត្រូវតែនិយាយរកកូនឱ្យបានច្រើនតាមដែលអាចធ្វើបាន ។




ត្រូវមានចិត្តអំណត់ ។ កូនអ្នកនឹងរៀនភាសាដោយសន្សឹមៗយូរជាងកុមារស្ដាប់ឮល្អ ។ អ្នកត្រូវតែធ្វើឱ្យកូនប្រើពាក្យនិយាយនៅពេលធ្វើអ្វីមួយ ឬឱ្យអ្វីមួយទៅកូនដោយមិនរងចាំកូនសុំអ្នកក៏ដោយ ។

កូនរបស់អ្នកនឹងនិយាយប្លែកពីគេ ។ កុមារថ្លង់ស្ទើរតែទាំងអស់និយាយយ៉ាងប្លែកពីកុមារស្ដាប់ឮ ។ លើកដំបូងអ្នកប្រហែលមានអារម្មណ៍ខ្មាសគេ ដោយសារសម្លេងកូននិយាយ នោះគឺជារឿងធម្មតា ។ នៅពេលអ្នកស៊ាំនឹងទម្លាប់នេះហើយ អ្នកអាចពន្យល់ប្រការនេះដល់មនុស្សឯទៀត ។



**កុមារនេះពាក់ឧបករណ៍ជំនួយការស្ដាប់នៅជុំវិញជងខ្លួន ។**

សហគមន៍ខុសៗគ្នាមានគំនិតប្លែកៗគ្នា អំពីរបៀបកុមារថ្លង់គួររៀនប្រាស្រ័យទាក់ទង ។ សាលាមត្តេយ្យមួយក្នុងប្រទេសឥណ្ឌាភាគនិរតី ព្យាយាមបង្រៀនកុមារតូចៗស្ដាប់មិនឮល្អ ឱ្យចេះនិយាយ អាន សរសេរ និងស្ដាប់ ។

ពួកគេព្យាយាមត្រៀមបម្រុងកុមារថ្លង់ ឱ្យចូលរៀនសាលាធម្មតានៅអាយុ5ឆ្នាំ ។ ដោយសារសាលារៀនមិនចង់ឱ្យកុមារអៀនខ្មាសព្រោះតែភាពថ្លង់ សាលារៀនទទូចឱ្យកុមារពាក់ឧបករណ៍ជំនួយការស្ដាប់ម្យ៉ាងដែលព័ទ្ធជុំវិញជងខ្លួន (សូមអានទំព័រ219) ។ ក្រៅពីធ្វើឱ្យសម្លេងឮខ្លាំង ឧបករណ៍ជំនួយការស្ដាប់ប្រភេទនេះជួយមនុស្សឱ្យបានឃើញ និងព្រមទទួលយកថាកុមារទាំងនេះគឺប្លែកពីគេឯង ។

## ផលប្រយោជន៍នៃការប្រើភាសានិយាយ

- កុមារដែលប្រាស្រ័យទាក់ទងបានដូចមនុស្សទាំងឡាយក្នុងសហគមន៍ នឹងមានមនុស្សជាច្រើនយល់អំពីខ្លួនថែមទៀត ។
- កុមារប្រើភាសានិយាយបានត្រៀមជាស្រេចសំរាប់ចូលសាលារៀន បើសិនជាសាលារៀននោះមិនប្រើភាសាសញ្ញា ។
- កុមារប្រើភាសានិយាយអាចរកឃើញថា មានការងាយស្រួលអានអក្សរ ពីព្រោះភាសាដែលកុមារនិយាយ និងភាសាសរសេរគឺស្រដៀងគ្នា ។




## ការលំបាកជាមួយការប្រើភាសានិយាយ

- ធម្មតា ការនិយាយប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពល្អសំរាប់កុមារស្តាប់ឮខ្លះៗតែប៉ុណ្ណោះ ( គ្រប់គ្រាន់នឹងស្តាប់ឮភាពខុសប្លែករវាងពាក្យជាច្រើន) ឬសំរាប់កុមារដែលក្លាយជាថ្លង់ក្រោយពេលចេះនិយាយហើយ ។
- កុមារអាចជួបការពិបាកអានដោយមើលបបូរមាត់ ពីព្រោះសម្លេងជាច្រើនមើលឃើញដូចៗគ្នានៅលើបបូរមាត់ ឬមិនអាចមើលដឹងនៅលើបបូរមាត់ ។ ឧទាហរណ៍ពាក្យ "ជា" "ជាង" "លាង" មើលឃើញដូចគ្នាទាំងអស់ ។ អ្នកអាចមើលមាត់ខ្លួនឯងមុខកញ្ចក់ ។



**ពាក្យ "ជា" "ជាង" "លាង" មើលឃើញដូចគ្នាទាំងអស់នៅលើបបូរមាត់ ។**

- កុមារដែលមានការពិបាកស្តាប់សម្លេងនិយាយ នឹងរកឃើញថាវាពិបាកនិយាយឱ្យច្បាស់ខ្លាំងណាស់ ពីព្រោះកុមារមិនអាចស្តាប់ឮសម្លេងខ្លួនឯងនិយាយ ។ មនុស្សផ្សេងទៀតក្រៅពីក្រុមគ្រួសារ អាចមិនយល់សម្លេងនិយាយរបស់កុមារ ។
- កុមារតូចៗមិនអាចអង្គុយរៀនមេរៀនភាសាដែលវែង ដោយស្ងៀមស្ងាត់នោះទេ ។
- ដោយសារការខិតខំដ៏ច្រើនលើសលប់លើការរៀននិយាយ និងរៀនយល់អ្វីៗដែលមនុស្សនិយាយ កុមារអាចនឹងបាត់បង់ពេលរៀនពីព្រឹត្តិការណ៍ទាំងឡាយដែលនៅជុំវិញថែមទៀត ។

## អ្វីៗដែលត្រូវគិតគូរ

ដោយសារក្រុមគ្រួសារនីមួយៗ និងកុមារម្នាក់ៗ មានតម្រូវការនិងលទ្ធភាពខុសៗគ្នានោះ គ្មានវិធីសាស្ត្រណាមួយដែលត្រឹមត្រូវជានិច្ចសំរាប់មនុស្សគ្រប់គ្នានោះទេ។ អ្វីដែលសំខាន់នោះ គឺត្រូវធ្វើការឱ្យល្អជាមួយធនធានដែលអ្នកមាន។ នៅពីរបីទំព័របន្ទាប់ទៀតមានផ្តល់ព័តិមាន និងសួរសំណួរខ្លះៗដែលអាចជួយអ្នកឱ្យទទួលបានលទ្ធផលល្អប្រសើរជាមួយកូន។

### ភាសាសញ្ញា

**អាចនឹង**មានជោគជ័យ បើសិនជា :-

- គ្រួសារអ្នកមានលទ្ធភាព មានឆន្ទៈចង់រៀន និងប្រើភាសាសញ្ញា។
- មានសៀវភៅ ឬមនុស្សដែលអាចបង្រៀនភាសាសញ្ញាដល់កូន និងក្រុមគ្រួសារអ្នក។
- មានសាលារៀនមនុស្សថ្លង់ក្នុងតំបន់របស់អ្នក ដែលបង្រៀនភាសាសញ្ញាដល់សិស្ស។



**អាចកាន់តែមាន**ជោគជ័យ**ច្រើនទៀត** បើសិនជា :-

- គ្រួសារអ្នកត្រូវមានចិត្តអំណត់ សមាជិកគ្រប់រូបខិតខំរៀន និងប្រើភាសាសញ្ញា។
- មានមនុស្សដែលអាចជួយបង្រៀនភាសាសញ្ញាពេញលេញដល់កូន និងគ្រួសាររបស់អ្នក។

### ភាសានិយាយ

**អាចនឹង**មានជោគជ័យ បើសិនជា :-

- កូនរបស់អ្នកអាចស្តាប់ឮសម្លេងនិយាយខ្លះៗ (អានជំពូកទី5 "រកឱ្យឃើញនូវអ្វីមួយដែលកូនកូនអាចស្តាប់ឮ)។
- កូនរបស់អ្នកចេះនិយាយ និងយល់ពាក្យមុនពេលបាត់បង់ការស្តាប់។
- កូនរបស់អ្នកបានរកឃើញថា ការអានដោយមើលបបូរមាត់គឺងាយស្រួលរៀន (កុមារខ្លះអាចធ្វើបានល្អជាងកុមារឯទៀត)។



**អាចកាន់តែមាន**ជោគជ័យ**ច្រើនទៀត** បើសិនជា :-

- កូនរបស់អ្នកមានឧបករណ៍ជំនួយការស្តាប់ ដែលកូនប្រើស្ទើរតែគ្រប់ពេល។
- មានអ្នកជំនាញនៅគ្លីនិក ឬកម្មវិធីសាលាមត្តេយ្យសំរាប់កុមារថ្លង់ ដើម្បីជួយកូនរបស់អ្នក។

## តើមានមនុស្សប៉ុន្មាននាក់ដែលកូនអ្នកអាចប្រាស្រ័យទាក់ទងជាមួយបាន?

ការប្រាស្រ័យទាក់ទងជាមួយមនុស្សជាច្រើននាក់ផ្សេងទៀត គឺជាការសំខាន់ណាស់ចំពោះកុមារមិនអាចស្តាប់ឮ។ កុមារដែលប្រើសញ្ញាប្រចាំផ្ទះ អាចប្រាស្រ័យទាក់ទងបានតែជាមួយមនុស្សនៅក្នុងផ្ទះរបស់ខ្លួនប៉ុណ្ណោះ។ កុមារដែលប្រើភាសាសញ្ញាពេញលេញ ឬភាសានិយាយមានលទ្ធភាពប្រាស្រ័យទាក់ទងជាមួយមនុស្សច្រើននាក់ទៀត។ កុមារដែលអាចអាន និងសរសេរភាសានិយាយក្នុងស្រុក កាន់តែមានលទ្ធភាពប្រាស្រ័យទាក់ទងជាមួយមនុស្សដ៏ច្រើននាក់ថែមទៀត។



ត្រូវធ្វើឱ្យប្រាកដថា មនុស្សទាំងអស់ធ្វើសញ្ញាពេលណាមានវត្តមានកុមារម្នាក់ដែលប្រើភាសាសញ្ញា។

ទោះជាអ្នកប្រើភាសានិយាយ ឬភាសាសញ្ញាក្តី ជាការសំខាន់ណាស់ដែលក្រុមគ្រួសារទាំងមូលត្រូវប្រើវាទាំងអស់គ្នា។ តាមវិធីនេះ កូនអ្នកអាចប្រាស្រ័យទាក់ទងជាមួយមនុស្សគ្រប់គ្នាក្នុងគ្រួសារ។ កូនអ្នកនឹងមានអារម្មណ៏ថា គេជាចំណែកមួយនៃគ្រួសារផងដែរ និងអាចរៀនពីព្រឹត្តិការណ៏ទាំងឡាយដែលនៅជុំវិញ តាមរយៈការជជែកគ្នាលេងរបស់ខ្លួន។

មនុស្សគ្មានបញ្ហាការស្តាប់អាចរៀនភាសាសញ្ញា បើសិនជាពួកគេចង់រៀនសូត្រ។ រឿងមួយនៅទំព័រទី150 បានរៀបរាប់អំពីរបៀបដែលមនុស្សនៅទីក្រុងមួយក្នុងប្រទេសប្រេស៊ីលរៀនប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់។

## ចុះបើសិនជាភាសាកំណើតរបស់កូនអ្នក មិនមែនជាភាសារបស់អ្នកទៅវិញ?

ការប្រើភាសាដូចគ្នាជួយដល់ការប្រាស្រ័យទាក់ទង។ ប៉ុន្តែជាញឹកញាប់ ភាសាសញ្ញាប្រើដោយកុមារថ្លង់ដើម្បីអភិវឌ្ឍគំនិតប្រាជ្ញា និងការរៀនសូត្រអំពីព្រឹត្តិការណ៏ទាំងឡាយដែលនៅជុំវិញ គឺមិនមែនជាភាសាដែលបានប្រើដោយក្រុមគ្រួសាររបស់ពួកគេទេ។ ឪពុកម្តាយ និងកុមារថ្លង់ភាគច្រើនដែលប្រើភាសាខុសពីគ្នា បានរកឃើញថា ពួកគេមានការពិបាកប្រាស្រ័យទាក់ទងជាមួយគ្នា។ ពួកគេអាចគ្មានអារម្មណ៏ស្និទ្ធស្នាលនឹងគ្នា និងទៅជាធុញទ្រាន់ដោយសារតែពិបាកយល់គ្នាទៅវិញទៅមកខ្លាំងពេក។ កុមារថ្លង់អាចមានអារម្មណ៏ដាច់ឆ្ងាយពីក្រុមគ្រួសារនៅក្នុងផ្ទះរបស់ខ្លួន។

ភាសាសញ្ញាអាចល្អបំផុតសំរាប់កុមារ តែវាមិនសូវស្រួលសំរាប់ក្រុមគ្រួសារ ឬវាអាចទាក់ទាញចំណាប់អារម្មណ៏មកលើកុមារដែលប្រាស្រ័យទាក់ទងចម្លែកជាងគេឯង។ ឪពុកម្តាយនៃកុមារថ្លង់អាចជួយកូនៗរៀនភាសាដែលត្រឹមត្រូវ ជាមួយការគាំទ្រពីសហគមន៏ទាំងឡាយរបស់ពួកគេ។



## តើកូនអ្នកចាប់ផ្ដើមមានបញ្ហាពិបាកក្នុងការស្ដាប់តាំងពីពេលណា?

បើសិនជាកូនអ្នកក្លាយជាថ្លង់ក្រោយពេលចេះនិយាយហើយ កូនអ្នកប្រហែលអាចនៅយល់បានខ្លះដោយមើលមាត់មនុស្សនិយាយគ្នា និងធ្វើឱ្យការនិយាយរបស់ខ្លួនប្រសើរឡើង។ កូនអាចបន្តអភិវឌ្ឍភាសាបាន ទោះបីជាក្រោយពេលបាត់បង់ការស្ដាប់ក៏ដោយ។ ប៉ុន្តែ បើសិនជាកូនអ្នកកើតមកគឺថ្លង់ទាំងស្រុង ឬមិនអាចស្ដាប់ឮសម្លេងនិយាយ កូនអ្នកពិតជាមានការពិបាកយ៉ាងខ្លាំង ឬក៏មិនអាចរៀនអានដោយមើលបបូរមាត់ ឬរៀននិយាយបាន។

**កុមារចេះនិយាយមុនពេលបាត់បង់ការស្ដាប់**
**អាចនិយាយបានល្អជាង កុមារថ្លង់ពីកំណើត។**




## តើកូនអ្នកអាចស្ដាប់ឮបានច្រើនប៉ុណ្ណា?

កាលណាកុមារអាចស្ដាប់ឮសម្លេងនិយាយបានកាន់តែច្រើន កុមារអាចប្រើការស្ដាប់ឮរបស់គេ ដើម្បីយល់ពាក្យ និងយល់ចំណែករបស់ពាក្យ ដើម្បីអានតាមបបូរមាត់ និងប្រហែលដើម្បីនិយាយបានកាន់តែច្រើនតាមនោះដែរ។ កុមារដែលមិនអាចស្ដាប់ឮសម្លេងនិយាយនឹងមានការពិបាករៀនបំណិនទាំងនេះ ឬមិនអាចរៀនកើត។

**កុមារីម្នាក់នេះ អាចស្ដាប់ឮសម្លេងនិយាយ នាង**
**អាចរៀនចេះនិយាយ និងអានតាមបបូរមាត់។**




**កុមារីនេះមិនអាចស្ដាប់ឮសម្លេងអ្វីទាំងអស់**
**គេពិតជាពិបាកយ៉ាងខ្លាំង ឬអានតាមបបូរ**
**មាត់មិនបាន ឬនិយាយមិនកើត។**



### តើកូនអ្នកនឹងត្រូវប្រើឧបករណ៍ជំនួយការស្តាប់ឬទេ?

ឧបករណ៍ជំនួយការស្តាប់អាចជួយកូនអ្នកឱ្យយល់ពាក្យ ប៉ុន្តែវាមិនអាចជួយកុមារគ្រប់រូបបានទេ ។ ជួនកាលមន្ត្រីសុខាភិបាលអាចផ្តល់យោបល់ឱ្យកូនអ្នកប្រើឧបករណ៍ជំនួយការស្តាប់ ។ សាកល្បងសុំយោបល់ពីឪពុកម្តាយដែលមានកូនប្រើឧបករណ៍ជំនួយការស្តាប់ និងត្រូវចាំថា កុមារម្នាក់ៗស្តាប់ឮខុសៗគ្នា ។ បើសិនជាអ្នកចង់ទិញឧបករណ៍ជំនួយការស្តាប់ឱ្យកូន សូមអានទំព័រ217 និង224 ដើម្បីជួយអ្នកសំរេចចិត្តបានត្រឹមត្រូវ ។

អ្នកលក់ឧបករណ៍ជំនួយការស្តាប់ អាចឱ្យព័ត៌មានអំពីវាដល់អ្នកបានខ្លះៗ ។ ប៉ុន្តែពួកគេមិនមែនជាមនុស្សល្អបំផុត សំរាប់សុំយោបល់ជានិច្ចនោះទេ ។ ពួកគេប្រហែលជាចាប់អារម្មណ៍រឿងលក់ផលិតផល ច្រើនជាងជួយអ្នករកអ្វីដែលត្រឹមត្រូវសំរាប់កូនរបស់អ្នក ។ ជួនកាលគ្លីនិក ឬហាងលក់ឧបករណ៍ជំនួយការស្តាប់អាចឱ្យកូនអ្នកសាកល្បងប្រើឧបករណ៍នោះ ពីរបីថ្ងៃ ឬមួយសប្តាហ៍ មុនពេលអ្នកសំរេចចិត្តទិញវា ។




**ឧបករណ៍ជំនួយការស្តាប់អាចជួយកូនអ្នក ប៉ុន្តែវាក៏ប្រហែលជាមិនអាចជួយកើតដែរ ។ បើសិនជាអ្នកមិនត្រូវការទិញវា មិនត្រូវឱ្យនរណាម្នាក់គាបសង្កត់អ្នកឱ្យទិញ ឬធ្វើឱ្យអ្នកមានកង្វល់ចិត្តឡើយ ។**

## តើខ្ញុំដឹងដោយរបៀបណា ថាកូនខ្ញុំរៀនចេះអ្វីមួយ?

ដើម្បីបានដឹងថាកុមាររៀនចេះភាសា វាទាមទារពេលវេលាច្រើន ។ ពីរបីខែ ឬច្រើនខែក្រោយពេលអ្នកបង្ហាត់ភាសាដល់កូន ចូរធ្វើការវាយតម្លៃដើម្បីឱ្យដឹងថា តើកូនចេះអ្វីខ្លះហើយ ។ សួរសំណួរទាំងនេះដល់ខ្លួនអ្នកផ្ទាល់ :-

- តើកូនយល់បានច្រើនជាងពីមុនឬទេ?
- តើកូនប្រើសញ្ញា ឬនិយាយបានញឹកញាប់ជាងពីមុនឬទេ?
- សំគាល់មើលថា តើកូនទំនងជាចាប់អារម្មណ៍រៀនប្រាស្រ័យទាក់ទងឬទេ? ឬក៏កូនធុញទ្រាន់កាន់តែច្រើនឡើង?
- ផ្អែកលើការមិនចេះភាសា ឬមិនយល់ភាសាឱ្យបានគ្រប់គ្រាន់ដើម្បីសំដែងអារម្មណ៍របស់ខ្លួន តើកូនមានបញ្ចេញអាកប្បកិរិយាពុំគប្បីខ្លះៗឬទេ ដែលវាបណ្តាលមកពីការធុញទ្រាន់?
- តើខ្ញុំរីករាយប្រាស្រ័យទាក់ទងជាមួយកូនឬទេ ឬក៏តែងទទួលបទពិសោធន៍ធុញទ្រាន់ជានិច្ច?
- ពេលខ្ញុំនិយាយពីអ្វីដែលកំពុងកើតឡើង តើយើងអាចប្រាស្រ័យទាក់ទងបានគ្រប់គ្រាន់ស្រួលបួលហើយឬនៅ ?
- តើកូនអាចប្រាស្រ័យទាក់ទងជាមួយមនុស្សឯទៀតបានល្អឬនៅ?
- តើកូនអាចយល់ព័ត៌មានបានដូចបងប្អូនប្រុសស្រីរបស់គេយល់ដែរឬទេ?

ជាញឹកញាប់ ឪពុកម្តាយតែងមានមនុស្សម្នាប្រាប់ថា ត្រូវតែជ្រើសយកភាសាមួយដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយកូន និងបន្តប្រើប្រាស់វាដោយគ្មានបញ្ហាចោទទេថា កូនរៀនបានច្រើន ឬតិចយ៉ាងណាក្តី ។ ជួនកាលភ្នាក់ងារសុខាភិបាលបានលើកទឹកចិត្តបែបនេះ ដោយសារពួកគេគិតថាវិធីមួយគឺត្រឹមត្រូវ ហើយវិធីផ្សេងៗទៀតគឺខុស ។ ប៉ុន្តែគ្មានវិធីណាមួយល្អឥតខ្ចោះនោះទេ ។




បើសិនជាកូនអ្នករៀនមិនចេះ និងធុញទ្រាន់កាន់តែច្រើនឡើង ចូរសាកល្បងរកដំណោះស្រាយផ្សេងទៀត ។ ផ្អែកលើការស្តាប់របស់កូន និងស្ថានភាពរបស់ខ្លួន ក្រុមគ្រួសារនីមួយៗត្រូវតែសំរេចចិត្តដោយខ្លួនឯង ។

## តើនរណាដឹងថាអ្វីល្អបំផុតសំរាប់កូនអ្នក?

មនុស្សជាច្រើនមានមតិយោបល់មុតមាំអំពីភាសាដែលត្រូវប្រើជាមួយកុមារថ្លង់ ។ ជាយូរឆ្នាំមកហើយ បណ្តាប្រទេសជាច្រើនបានយកភាសានិយាយជាច្បាប់ដើម្បីប្រើជាមួយកុមារថ្លង់ (ការប្រាស្រ័យទាក់ទងតាមមាត់) ។ ជួនកាលមន្ត្រីសុខាភិបាល និងមន្ត្រីអប់រំប្រាប់អ្នកថា កុមារថ្លង់**គ្រប់រូប**អាចរៀននិយាយ ។

នេះគឺមិនពិតទេ ទោះបីជាពួកគេអាចណែនាំអ្នកដល់កុមារថ្លង់ដែលនិយាយបានល្អឥតខ្ចោះក៏ដោយ ។

ពេលខ្លះអ្នកឯកទេសប្រាប់អ្នកនូវអ្វីដែលពួកគេផ្ទាល់បានរៀនច្រើនឆ្នាំមកហើយ ។ ពួកគេអាចប្រាប់អ្នកថា ត្រូវតែប្រើភាសានិយាយជាមួយកូន ឬបើមិនអញ្ចឹងទេនោះ អ្នកគ្មានភាពទទួលខុសត្រូវចំពោះកូន ។ នេះគឺមិនពិតទេ អ្នកស្គាល់កូន និងស្ថានភាពគ្រួសាររបស់អ្នកច្បាស់ជាងពួកគេទៅទៀត ។



## ប្រើភាសាដែលកូនរបស់អ្នកអាចរៀនបាន

កូនអ្នកត្រូវការសំដែងអារម្មណ៍របស់ខ្លួន និងត្រូវការយល់ពីមនុស្សឯទៀត។ កុមារត្រូវការចេះដឹងឱ្យបានច្រើនជាងការនិយាយ "ម៉ែ" ឬ "ពុក"។ កុមារត្រូវការអភិវឌ្ឍលទ្ធភាពការស្តាប់ យល់អ្វីដែលមនុស្សម្នាបាននិយាយរក ឆ្លើយតប និងប្រាស្រ័យទាក់ទងជាមួយមនុស្សឯទៀតបានស្រួលបួល និងពេញលេញតាមដែលអាចធ្វើបាន។




ឪពុកម្តាយ និងអ្នកថែទាំអាចជួយបង្ហាត់កុមារតាមវិធីដែលក្មេងអាចក្រេបយកចំណេះបាន។ បើសិនជាអ្នករកឃើញថា កុមារមិនអាចរៀនភាសាសញ្ញាកើត ចូររិះគិតជួយក្មេងរៀនភាសានិយាយវិញ។ ឬបើមើលទៅកុមារទំនងជាមិនយល់ភាសានិយាយ សូមសាកល្បងជួយក្មេងរៀនភាសាសញ្ញាវិញ។ កាលបើកុមារចេះស្គាល់ និងចេះប្រើភាសាមួយបានល្អហើយ កុមារនឹងងាយស្រួលរៀនភាសាផ្សេងបានច្រើនទៀត។

សួរមតិយោបល់ពីឪពុកម្តាយនៃកុមារដែលបានរៀនភាសាមួយ ជាភាសាសញ្ញា ឬជាភាសានិយាយក្តី ឬក៏ទាំងពីរភាសា មតិយោបល់ទាំងនោះនឹងជួយដល់ឪពុកម្តាយទាំងឡាយណា ដែលព្យាយាមបង្ហាត់តែភាសាមួយដល់កូនរបស់ខ្លួន។




បើទោះជាពួកគេមិនអាចស្តាប់ឮពាក្យ កុមារថ្លង់នៅតែអាចរៀនប្រើភាសាសរសេរបាន។ កុមាថ្លង់រៀនដោយចំណាំពាក្យនោះសរសេរយ៉ាងម៉េច ជាជាងវាមានសម្លេងយ៉ាងម៉េច។ ពួកគេឃើញទំនាក់ទំនងរវាងនិមិត្តសញ្ញា (ភាសាសរសេររបស់ចិនមានដំណើរការបែបនេះផងដែរ)។ កុមារថ្លង់ដែលរៀនប្រើភាសាមួយទាន់ពេលវេលា ទោះជាភាសានិយាយ ឬភាសាសញ្ញាក្តី ពួកគេនឹងអាចចេះអាន និងសរសេរបានល្អ។ បើសិនជាកុមារថ្លង់បានជួបមនុស្សថ្លង់ពេញវ័យដែលអាចអានអក្សរបាន នោះវានឹងជួយដល់ពួកគេផងដែរ។




កាលនៅពីកុមារ ពេលខ្លះមនុស្សថ្លង់មិនបានរៀនប្រាស្រ័យទាក់ទងឡើយ។ ទោះជាវាល្អប្រសើរសំរាប់កុមារតូចៗរៀនការប្រាស្រ័យទាក់ទងក៏ដោយ កុមារធំៗ និងមនុស្សពេញវ័យក៏អាចរៀនប្រាស្រ័យទាក់ទងបានផងដែរ។ ជំពូកទី៨ និងទី៩ និយាយពីវិធីសាស្ត្រដែលអ្នកអាចប្រើដើម្បីបង្រៀនកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អ។

- ដើម្បីជួយកុមាររៀនភាសាសញ្ញា សូមអានជំពូកទី៨។
- ដើម្បីជួយកុមាររៀនភាសានិយាយ សូមអានជំពូកទី៩។

## ធនធានដែលអាចជួយបាន

របៀបដែលកុមារថ្លង់ ឬកុមារមិនអាចស្តាប់ឮល្អរៀនភាសា គឺពឹងផ្អែកទៅលើកុមារផ្ទាល់ ធនធានដែលមានក្នុងក្រុមគ្រួសារ អ្នកថែទាំ និងសហគមន៍របស់ពួកគេ។ វានឹងមានការងាយស្រួលសំរាប់ឪពុកម្តាយ និងអ្នកថែទាំជួយឱ្យកុមាររៀនភាសាមួយ បើសិនជាពួកគេបានការគាំទ្រពីគ្នាទៅវិញទៅមក ពីសហគមន៍អង្គការ ពីសាលារៀនសំរាប់កុមារថ្លង់ ឬពីអង្គការផ្សេងៗទៀត។




ធនធានក្នុងសហគមន៍អាចរួមបញ្ចូលទាំង :-

- សហគមន៍មនុស្សថ្លង់ក្នុងតំបន់ ក្លឹបមនុស្សថ្លង់ ឬនរណាម្នាក់ដែលអាចបង្រៀនភាសាសញ្ញាដល់កូន និងគ្រួសារអ្នក។
- កម្មវិធីស្តារមូលដ្ឋានសហគមន៍ ក្រុមឪពុកម្តាយ និងក្រុមមូលដ្ឋានសហគមន៍ផ្សេងៗទៀត។
- គ្រូបង្រៀននៅសាលារៀនក្នុងស្រុកភូមិ កុមារថ្លង់ធំៗ និងមនុស្សឯទៀតដែលព្យាយាមបង្រៀនកូនថ្លង់របស់អ្នក។
- សាលារៀនក្នុងសហគមន៍ ដែលអាចបង្រៀនកុមារថ្លង់។
- សៀវភៅ និងកាសែតវីដេអូអំពីរឿង និងអត្ថបទខ្លីៗដែលមានប្រយោជន៍ចំពោះមនុស្សថ្លង់ បទពិសោធន៍នៃជីវិតក្នុងនាមជាមនុស្សថ្លង់ និងរឿងរបស់មនុស្សថ្លង់ទាំងឡាយណាដែលមានជោគជ័យក្នុងជីវិត។

ការរៀនសញ្ញាជួយកូនអ្នកឱ្យបានស្គាល់មនុស្សថ្លង់ឯទៀតផងដែរ។ កូននឹងដឹងថាមនុស្សថ្លង់ គឺជាចំណែកមួយសំខាន់នៃសហគមន៍។ បើសិនជាមានមនុស្សថ្លង់ក្នុងសហគមន៍របស់អ្នក ស្នើសុំឱ្យគេចំណាយពេលជាមួយគ្រួសារអ្នក និងឱ្យគេជួយបង្រៀនអ្នកទាំងអស់គ្នាឱ្យចេះធ្វើសញ្ញា។




បើសិនជាគ្មានមនុស្សថ្លង់នៅក្នុងតំបន់របស់អ្នក ព្យាយាមទាក់ទងទៅសមាគមមនុស្សថ្លង់ប្រចាំប្រទេសរបស់អ្នក ឬសាលារៀនសំរាប់កុមារថ្លង់។ ព្យាយាមរកសៀវភៅដើម្បីជួយអ្នករៀនធ្វើសញ្ញា។ បើសិនជាករណីនេះមិនអាចទៅរួច ចូរបន្តប្រើសញ្ញាក្នុងស្រុកភូមិ និងកាយវិការ ព្រមទាំងបង្កើតសញ្ញាដោយខ្លួនឯង។

អ្នកត្រូវប្រាស្រ័យទាក់ទងនឹងកូនឱ្យបានច្រើនតាមដែលអាចធ្វើបាន នោះគឺជាការសំខាន់។ កុមារត្រូវការឱ្យមនុស្សស្រឡាញ់ លើកទឹកចិត្ត និងតម្រង់ទិសដល់ពួកគេលើសពីអ្វីៗទាំងអស់។ ប្រការនេះនឹងជួយភាសាឱ្យក្លាយជាចំណែកមួយនៃជីវិតរស់នៅរបស់កុមារ។

**កូនអ្នកគួរតែដឹងថា ការស្រឡាញ់ និងសន្ដោសប្រណីរបស់អ្នកមិនបាន ផ្អែកលើលទ្ធភាពនិយាយ ឬធ្វើ សញ្ញារបស់គេឡើយ។**

